## ព័ត៌មាន និងការចូលរួម

- ព័ត៌មានពាក់ព័ន្ធស្តីពីជំងឺរាតត្បាត និងការឆ្លើយតបនឹងជំងឺកូវីដ-១៩ គួរត្រូវបានផ្សព្វផ្សាយដល់មនុស្សទាំងអស់ ដោយមិនមានការលើកលែង។ ការនេះទាមទារធ្វើឱ្យព័ត៌មានដែលមានស្រាប់តាមទម្រង់ និងភាសាផ្សេងៗដែលងាយស្រួលយល់ រួមមាន ភាសាជនជាតិដើមភាគតិច និងភាសារបស់ជនជាតិភាគតិច ជាតិពន្ធុ សាសនា និងព័ត៌មានសមស្របសម្រាប់ក្រុមមនុស្សមួយចំនួនដែលមានសេចក្តីត្រូវការជាក់លាក់ រួមទាំង អ្នកពិការភ្នែក និងមនុស្សថ្លង់ និងបានទៅដល់អ្នកទាំងឡាយដែលមិនចេះអានអក្សរ ឬអានអក្សរនៅមានកម្រិត ឬមិនមានអ៊ីនធឺណិត។
- ការចូលប្រើអ៊ីនធឺណិត គឺសំខាន់ចាំបាច់ ដើម្បីធានាឲ្យព័ត៌មានបានទៅដល់អ្នកដែលរងផលប៉ះពាល់ដោយវីរុស។ រដ្ឋាភិបាល គួរតែបញ្ឈប់រាល់ការរំខាន ឬការបិទអ៊ីនធឺណិតដែលមានស្រាប់ ហើយអនុញ្ញាតឱ្យប្រើប្រាស់អ៊ីនធឺណិតតទៅទៀត។ រដ្ឋាភិបាលទាំងឡាយ ក៏គួរតែធ្វើការដើម្បីធានាលទ្ធភាពទទួលបានសេវាអ៊ីនធឺណិតដែលមានលក្ខណៈទូលំទូលាយបំផុត ដោយចាត់វិធានការដើម្បីភ្ជាប់ការបែងចែកឌីជីថល រួមទាំង ការបែងចែកឌីជីថលយេនឌ័រផងដែរ
- ប្រជាជនមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរស់នៅរបស់ខ្លួន។ ដែលមានលក្ខណៈបើកចំហ និងមានតម្លាភាព ហើយដោយមានការចូលពីប្រជាជនដែលរងផលប៉ះពាល់ដោយការធ្វើការសម្រេចចិត្ត គឺជាគន្លឹះក្នុងការធានាឱ្យប្រជាជនចូលរួមក្នុងវិធានការ ដែលធ្វើឡើងដើម្បីការពារសុខភាពរបស់ពួកគេ និងរបស់ប្រជាជនទូទៅផ្សេងទៀត ហើយថាវិធានការទាំងនោះក៏ឆ្លុះបញ្ចាំងផងដែរ ពីស្ថានភាព និងតម្រូវការជាក់លាក់របស់ពួកគេ។
- អ្នកវិជ្ជាជីវៈពេទ្យ និងអ្នកជំនាញពាក់ព័ន្ធ ត្រូវតែអាចនិយាយបានដោយសេរី និងចែករំលែកព័ត៌មានដល់គ្នាទៅវិញទៅមក និងដល់សាធារណជន។ អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ គួរតែអាចរាយការណ៍អំពីជំងឺរាតត្បាត រួមទាំង ការផ្សព្វផ្សាយដែលមានសារៈសំខាន់អំពីការឆ្លើយតបរបស់រដ្ឋាភិបាល ដោយមិនមានការភ័យខ្លាច ឬការត្រួតពិនិត្យ។ កិច្ចខិតខំប្រឹងប្រែងរួមគ្នា គួរធ្វើឡើងនៅថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីប្រឆាំងនឹងព័ត៌មានមិនពិត ឬព័ត៌មានបំភ្លើសដែលជំរុញឱ្យមានការភ័យខ្លាច និងការរើសអើង។
- ការបញ្ចូលទស្សនទាន សំឡេង និងចំណេះដឹងរបស់ស្ត្រី ក្នុងការរៀបចំ និងការឆ្លើយតបចំពោះការផ្ទុះឡើងនៃជំងឺ គឺចាំបាច់ រួមទាំងការធានាឱ្យមានភាពជាតំណាង ការចូលរួម និងតួនាទីជាអ្នកដឹកនាំរបស់ពួកគេ នៅក្នុងវេទិកាជំងឺកូវីដ-១៩ ថ្នាក់ជាតិ ថ្នាក់តំបន់ និងពិភពលោក។